# បណ្តាញយុវជនកម្ពុជា
CAMBODIAN YOUTH NETWORK

# សេចក្តីថ្លែងការណ៍

## បណ្តាញយុវជនកម្ពុជា (CYN) ចេញផ្សាយរបាយការណ៍ស៊ើបអង្កេត ស្តីពី ដែនជម្រកសត្វព្រៃ ព្រៃឡង់ក្នុងខេត្តស្ទឹងត្រែងនិងព្រះវិហារកំពុងប្រឈមនឹង ការកាប់ទន្ទ្រានដីព្រៃយ៉ាងអាថ៌កំបាំង

**រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩**

បណ្តាញយុវជនកម្ពុជា (CYN) ចេញផ្សាយរបាយការណ៍ស៊ើបអង្កេតនិងស្រាវជ្រាវស្តីពី ដែនជម្រកសត្វព្រៃ ព្រៃឡង់ក្នុងខេត្តស្ទឹងត្រែងនិងព្រះវិហារកំពុងប្រឈមនឹងការកាប់ទន្ទ្រានដីព្រៃយ៉ាងអាថ៌កំបាំង បានធ្វើឡើងចាប់ពីថ្ងៃទី១៣ ខែកក្កដា ដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩។ ការស៊ើបអង្កេត និងស្រាវជ្រាវនេះ ធ្វើឡើងនៅក្នុងឃុំអន្លង់ជ្រៃ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង និងស្រុកឆែប ខេត្តព្រះវិហារ តាមរយៈទិន្នន័យដែលបានមកពីការសម្ភាសន៍ជាមួយប្រជាពលរដ្ឋនៅក្នុងតំបន់, អាជ្ញាធរឃុំ, ការចុះល្បាត, ការត្រួតពិនិត្យទីតាំងនៃការកាប់និងទន្ទ្រានដីព្រៃជាក់ស្តែង, ការថតរូប, វីដេអូ និងការកំណត់កូអរដោនេភូមិសាស្ត្រនៃការកាប់ទន្ទ្រានដីព្រៃក្នុងដែនជម្រកសត្វព្រៃព្រៃឡង់។

របាយការណ៍នេះ រកឃើញថាព្រៃស្រោងពណ៌បៃតងក្រាសនៅក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់ក្នុងក្នុងឃុំអន្លង់ជ្រៃ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង និងនៅឃុំឆែប ស្រុកឆែប ខេត្តព្រះវិហារ ដែលមានព្រំប្រទល់ជាប់គ្នាបាននឹងកំពុងទទួលរងការគំរាមកំហែងពីការទន្ទ្រានកាន់កាប់ដីខុសច្បាប់ច្រើនរយហិកតា និងជាច្រើនកន្លែងផ្សេងៗគ្នា។ នៅក្នុងទំហំដីព្រៃប្រមាណ ១៧៦១ ហិកតា ត្រូវបានរកឃើញថា ដីព្រៃជាច្រើនរយហិកតាត្រូវបានកាប់រានរួចរាល់ (កាប់ចោះជាប្រឡោះៗ) ត្រូវបានគេបាញ់ថ្នាំលើដើមឈើ និងកាប់ដាក់តម្រុយដើម្បីកំណត់ក្បាលដី និងការត្រួសដើងក្រោមស្ទើរគ្រប់តំបន់។ ទំហំគម្របព្រៃឈើដែលកំពុងទទួលរងការគំរាមកំហែងនិងការបាត់បង់អាចមានទំហំរហូតដល់ប្រមាណ ៣០០០ ហិកតា ដោយសារតែការកាប់រានមានទាំងនៅក្នុងនិងក្រៅតំបន់ដែលបានស៊ើបអង្កេតខាងលើ។ មានភស្តុតាងជាច្រើនបញ្ជាក់ថា ការកាប់រាននិងទន្ទ្រានដីព្រៃ គឺធ្វើឡើងក្រោយពេលដែលព្រៃឡង់ត្រូវបានបង្កើតទៅជាដែនជម្រកសត្វព្រៃ។

មូលហេតុសំខាន់នៃការទន្ទ្រាននិងការកាប់រានដីព្រៃ គឺធ្វើឡើងដើម្បីកាន់កាប់ដីនិងបំប្លែងដីទៅជាដីសម្រាប់ដាំដំណាំកសិឧស្សាហកម្មដែលមានដូចជា ចម្ការដំឡូង និងចម្ការចន្ទី ដោយអ្នកចំណូលស្រុក និងអ្នកដែលមិនត្រូវបានកំណត់អត្តសញ្ញាណច្បាស់លាស់។ លើសពីនេះ ចាប់តាំងពីមានលំហូរចូលនៃប្រជាពលរដ្ឋចំណូលស្រុកដែលបានចូលមកទិញនិងកាប់រានដីព្រៃកាន់កាប់ជាកម្មសិទ្ធិជាច្រើនហិកតាធ្វើដំណាំកសិឧស្សាហកម្ម។ អ្នកភូមិខ្លះដែលមិនមានដីចម្ការ ឬមានដីចម្ការតិចតួចក៏បានចាប់ផ្តើមរានដីព្រៃដើម្បីពង្រីកដីចម្ការរបស់ខ្លួន និងចាប់ផ្តើមកាន់កាប់ដីជាកម្មសិទ្ធិផងដែរ ក្នុងគោលបំណងដាំដំណាំចន្ទី និងដំឡូងមីតាមអ្នកចំណូលស្រុកផងដែរ។

លើសពីនេះ របាយការណ៍ក៏បានរកឃើញថា ការទន្ទ្រានដីព្រៃនៅក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់ គឺផ្ទុយនឹងច្បាប់ភូមិបាល និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។ ការអនុវត្តច្បាប់និងការបំពេញមុខងាររបស់អាជ្ញាធរពាក់ព័ន្ធជាពិសេសមន្ត្រីឧទ្យានុរក្ស និងមន្ត្រីរដ្ឋបាលឃុំនៅមានកម្រិតនៅឡើយ ដែលជាហេតុធ្វើឱ្យព្រៃឡង់នៅតែស្ថិតនៅក្រោមការគំរាមកំហែងពីការកាប់ឈើ ការទន្ទ្រានដីព្រៃ និងការបរបាញ់សត្វខុសច្បាប់ដែលកំពុងតែប៉ះពាល់ដល់និរន្តរភាពព្រៃឡង់ និងប្រព័ន្ធអេកូឡូស៊ីរបស់វា។ ចំពោះ លិខិតបទដ្ឋានមួយចំនួនទៀតដូចជា សារាចរណែនាំលេខ ០៥ ស្តីពី វិធានការចាំបាច់នានាក្នុងការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ ស្របតាមគោលនយោបាយកំណែទម្រង់ស៊ីជម្រៅលើការគ្រប់គ្រងធនធានធម្មជាតិ និងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ៩៣ សសរ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពី ការបង្កើតគណៈកម្មការជាតិ ដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រានដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីវាតយកដីធ្វើជាកម្មសិទ្ធិ ក៏ពុំទាន់មានការអនុវត្តឱ្យបានប្រសើរដែរ។

របាយការណ៍ស៊ើបអង្កេត និងស្រាវជ្រាវនេះ ក៏បានផ្តល់នូវអនុសាសន៍មួយចំនួន និងអាចជួយផ្តល់ព័ត៌មាន និងភស្តុតាងបន្ថែមទៀតដល់អាជ្ញាធរមានសមត្ថកិច្ចជាពិសេសក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្តស្ទឹងត្រែងនិងព្រះវិហារ ព្រមទាំងអាជ្ញាធររដ្ឋបាលដែនដីក្នុងតំបន់ដែលកើតហេតុ ពង្រឹងការអនុវត្តច្បាប់ បង្ការនិងបង្ក្រាបរាល់សកម្មភាពទាំងឡាយណាដែលធ្វើឱ្យខូចខាតធ្ងន់ធ្ងរដល់ដែនជម្រកសត្វព្រៃព្រៃឡង់ និងជាប្រយោជន៍ក្នុងការចូលរួមការពារព្រៃឡង់ឱ្យមាននិរន្តរភាព។

***<u>សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:</u>***


- លោក **ស ម៉ូរី**, អនុប្រធានបណ្តាញយុវជនកម្ពុជា, លេខទូរស័ព្ទ +៨៥៥ ១៦ ៩៣០ ៥៨៨
- លោក **សែន សទ្ធា**, ក្រុមស្នូលបណ្តាញសហគមន៍ព្រៃឡង់ ខេត្តស្ទឹងត្រែង, លេខទូរស័ព្ទ +៨៥៥ ៨៧ ៨៤៦ ១៨៣